**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន

# របាយការណ៍
# ស្តីពីវឌ្ឍនភាពប្រចាំខែកក្កដា ឆ្នាំ២០១៧

-**សូមគោរព ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

-**សូមគោរព ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ** ជាទីគោរព !

-**សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលមានវត្តមានក្នុងអង្គប្រជុំថ្ងៃនេះ** ជាទីរាប់អាន !

## I.លទ្ធផលការងារ

១.មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិនបានសហការជាមួយរដ្ឋបាលខេត្តប៉ៃលិនក្នុងការដោះស្រាយការយកសេវាក្រៅផ្លូវការចំពោះការនាំចេញកសិផលទៅប្រទេសថៃតាមច្រកអន្តរជាតិព្រំ បានដោយជោគជ័យ គឺមានន័យថា បានបញ្ឈប់ទាំងស្រុងចំពោះការយកសេវាក្រៅផ្លូវការនេះ ។

២.បានសម្របសម្រួលជាមួយសមាគមអ្នកនាំចេញដំឡូងមីក្រុង-ស្រុក ក្នុងខេត្តប៉ៃលិន អោយជួយទទួលទិញពោតក្រហមពីប្រជាកសិករ ដើម្បីសម្ងួតលក់អោយក្រុមហ៊ុន ស៊ី.ភី និង សម្រាប់ការនាំចេញទៅប្រទេសថៃ ។

៣.បានសម្របសម្រួលជាមួយ ក្រុមហ៊ុន ស៊ី.ភី ប្រចាំខេត្តប៉ៃលិន អោយជួយទទួលទិញពោតក្រហមពីប្រជាកសិករ និងពីបណ្តាក្រុមហ៊ុនទទួលទិញ-លក់កសិផលក្នុងខេត្តប៉ៃលិន ។ ក្រុមហ៊ុន ស៊ី.ភី បានឯកភាពជាគោលការ តែមានលក្ខខ័ណ្ឌដូចខាងក្រោម៖

ក. ពោតក្រហមស្ងួល ដែលមានសំណើមពី ៣០% ចុះ មានតម្លៃចន្លោះពី ៤៩០៛-៤៩២៛/គ.ក

ខ.ពោតក្រហមគ្រាប់ដែលមានសំណើមចាប់ពី១៤% ចុះ មានតម្លៃចន្លោះពី ៩៣០,៣៛-៩៣៤,៨៛/គ.ក

ក្រុមហ៊ុន ស៊ី.ភី ប្រចាំខេត្តប៉ៃលិន មានលទ្ធភាពទទួលទិញកសិផលដូចខាងក្រោម៖

ក.ពោតក្រហមស្ងួល ពី ចំនួន ២០០ តោន ទៅ ៤០០ តោន ក្នុង ១ថ្ងៃ

ខ.ពោតក្រហមគ្រាប់ ពី ១,០០០ តោន ទៅ ១,២០០ តោន ក្នុង ១ថ្ងៃ

គ.ដំឡូងមីស្ងួត ពី ចំនួន ២,០០០-៣,៥០០ តោន / ១ថ្ងៃ

ក្រុមហ៊ុន ស៊ី.ភី ក្នុងខេត្តប៉ៃលិន មានតម្រូវការទិញពោតក្រហម ប្រហែល ៦០,០០០តោន (ហុកសិបពាន់តោន) ក្នុង ១ឆ្នាំ

**ទីផ្សារចែកចាយចំណីសត្វរបស់ក្រុមហ៊ុន** CP

ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ

៣.ការផ្សព្វផ្សាយការផ្តល់កម្ចីពីធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីប្រមូលទិញកសិផលគ្រប់ប្រភេទ ដោយសមាគមអ្នកនាំចេញដំឡូងមីក្រុង/ស្រុក បានសម្រេចយកឥណទាន ពីរដំណាក់កាលដូចខាងក្រោម:

-ឥណទានរយៈពេលវែង ( សាងឡសម្ងួត ឃ្លាំងស្តុកទុក និងលានហាល )

-ឥណទានរយៈពេលខ្លី ( ទិញបង្វិលប្រចាំថ្ងៃ )

៤.ទំហំការនាំចេញស្វាយ (ច្រកទ្វារអន្តរជាតិព្រំ) ពីរឆ្នាំកន្លងមក មានសភាពល្អ គិតជាមធ្យម ក្នុងមួយ ថ្ងៃចន្លោះពី ៨០,០០០ ទៅ ១០០,០០០ $ ក្នុងមួយថ្ងៃ ។ ស្វាយបេះពី ខែ កញ្ញា ដល់ ខែ មិថុនា ចំនួន ០៨ ខែ តម្លៃគិតជាមធ្យមពី ៥០០-១,៥០០៛/១ Kg មានក្រុមហ៊ុន ចំនួន១០ បញ្ជាទិញពី២៤ ខេត្ត ។

## II.បញ្ហាប្រឈម

-ខ្វះឡសម្ងួត ឃ្លាំងស្តុក និងលានហាល តម្រូវតាមស្តង់ដា

-លក្ខខណ្ឌរបស់ធនាគារតឹងរឹងដល់បណ្តាលក្រុមហ៊ុន សហគ្រាស ទិញ-លក់កសិផល

-ស្នើដល់ធនាគារកាត់បន្ថយលក្ខខណ្ឌ និងសម្រួលភាពងាយស្រួលដល់ការកម្ចី

-ក្រុមហ៊ុន សហគ្រាស គ្មានពោតដាក់បញ្ចាំទេ ( ទិញ-លក់ភ្លាម )

## III.សកម្មភាពការងារបន្ត

-ចូលមហោស្រពពិព័រណ៍ បណ្តាំស្ល លើកទី១៨ នៅក្នុងខេត្តប៉ៃលិន

-គ្រោងរៀបចំ ស្តីពីការផ្គត់ផ្គង់សង្វាក់ផលិតកម្មទីផ្សារផ្លែមៀនប៉ៃលិនឲ្យបាន ចំនួន ៥,០០០ តោន នាំចេញទៅប្រទេសចិន

-ចុះ MOU ជាមួយប្រទេសចិន និងសាងសង់កន្លែងសម្ងួត វេចខ្ចប់នៅក្នុងខេត្តប៉ៃលិន

-ការពិភាក្សាលើសង្វាក់ផលិតកម្មទីផ្សារមៀនប៉ៃលិន ដែលមានសមាសភាពទាំង១០ ខេត្ត ចូលរួម ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានសហគមន៍ មៀនខេត្តនីមួយៗ ។

-រៀបចំសមាគមអ្នកបញ្ជាទិញបន្លែ ដើម្បីងាយស្រួលក្នុងការផ្គត់ផ្គង់តម្រូវការទីផ្សារ

-រៀបចំសមាគមអ្នកទិញ-លក់ លោហៈធាតុ ត្បូងថ្ម មានតម្លៃ

## IV.សំណូមពរ

មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន សូមសំណូមពរដូចខាងក្រោមៈ

១. សូមក្រសួងជួយផ្តល់រថយន្ត ចំនួន ០១គ្រឿង សម្រាប់ប្រើប្រាស់ក្នុងមន្ទីរ ដើម្បីចុះមូលដ្ឋាន និងជួយសម្របសម្រួលការទិញ-លក់កសិផលតាមបណ្តាក្រុមហ៊ុនទទួលទិញ-លក់កសិផលក្នុងខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ។

២. សូមក្រសួងមេត្តាជួយផ្តល់មន្ត្រីជាប់កិច្ចសន្យា ចំនួន ០២រូប បន្ថែមទៀត

# អរគុណ!